## ការិយាល័យលីកាដូ តាមបណ្ដាខេត្ត

**លីកាដូបន្ទាយមានជ័យ** ភូមិ៣ ឃុំព្រះពន្លា ស្រុកសេរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ
លេខទូរស័ព្ទ : ០៥៤ ៩៥៨ ៨៦១

**លីកាដូបាត់ដំបង** ផ្ទះលេខ ៣១២ ក្រុម២១ ភូមិកំពង់ក្របី ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង
លេខទូរស័ព្ទ: ០៥៣ ៩៥២ ៨២៨

**លីកាដូកំពង់ចាម** ក្រុម៤ ភូមិ៦ ឃុំវាលវង់ ស្រុកកំពង់ចាម ខេត្តកំពង់ចាម
លេខទូរស័ព្ទ: ០៤២ ៩៤១ ៤៦៤

**លីកាដូកំពង់ឆ្នាំង** ផ្ទះលេខ២ ភូមិ២ ឃុំប្អេរ ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង
លេខទូរស័ព្ទ : ០២៦ ៩៨៨ ៦៣៧

**លីកាដូកំពង់ស្ពឺ** ផ្ទះលេខដីឡូបេ៤ ផ្លូវជាតិលេខ៤ ភូមិពាណិជ្ជកម្ម ឃុំរកាធំ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ
លេខទូរស័ព្ទ: ០២៥ ៩៨៧ ២២០

**លីកាដូកំពង់ធំ** ផ្ទះលេខ២៥៤ ភូមិកំពង់ធំ ឃុំកំពង់រទេះ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ
លេខទូរស័ព្ទ: ០៦២ ៩៦១ ២៩២

**លីកាដូកំពត** ផ្ទះលេខ៧៨ ភូមិ១ឧសភា ឃុំកំពង់បាយ ស្រុកកំពង់បាយ ខេត្តកំពត
លេខទូរស័ព្ទ : ០៣៣ ៩៣២ ៦៦៣

**លីកាដូកោះកុង** ផ្ទះលេខក្រោយមន្ទីរពាណិជ្ជកម្ម ភូមិ២ ឃុំសាច់មានជ័យ ស្រុកស្មាច់មានជ័យ កោះកុង
លេខទូរស័ព្ទ: ០៣៥ ៩៣៦ ១១៦

**លីកាដូពោធិសាត់** ភូមិមាន់ចៃ ឃុំព្រៃញី ស្រុកសំពៅមាស ខេត្តពោធិសាត់
លេខទូរស័ព្ទ: ០៥២ ៩៥១ ៤៩៦

**លីកាដូសៀមរាប** ផ្ទះលេខ៣៣៩ ភូមិមណ្ឌល៣ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប
លេខទូរស័ព្ទ : ០៦៣ ៩៦៤ ០៦៦

**លីកាដូក្រុងព្រះសីហនុ** ផ្ទះលេខ២៩១ ផ្លូវឯករាជ្យ មណ្ឌល២ សង្កាត់២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ
លេខទូរស័ព្ទ: ០៣៤ ៩៣៣ ៧១៦

**លីកាដូស្វាយរៀង** ភូមិរោងបន្លែ ឃុំស្វាយរៀង ស្រុកស្វាយរៀង ខេត្តស្វាយរៀង
លេខទូរស័ព្ទ: ០៤៤ ៩៤៥ ៨៣៣

## ការិយាល័យកណ្ដាលអង្គការ លីកាដូ


អាសយដ្ឋានផ្ទះលេខ: ១៦ ផ្លូវលេខ ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ
លេខទូរស័ព្ទ: ០២៣ ៧២៧ ១០២
អ៊ីម៉ែល: contact@licadho-cambodia.org
វែបសាយ: http://www.licadho-cambodia.org



ការបោះពុម្ពនេះត្រូវបានផលិតក្រោមជំនួយហិរញ្ញវត្ថុរបស់សហគមន៍អ៊ឺរ៉ុប។ មាតិកានៃការបោះពុម្ពនេះ គឺជាការទទួលខុសត្រូវរបស់លីកាដូតែមួយគត់ហើយមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់សហគមន៍អ៊ឺរ៉ុបឡើយ ។


# យល់ដឹងពីសិទ្ធិរបស់អ្នក

## សេរីភាពក្នុងការធ្វើដំណើរ

- ប៉ូលិសមិនមានសិទ្ធិហាមឃាត់លោក-អ្នកមិនឱ្យធ្វើដំណើរតាមបណ្ដាខេត្តឬទៅទីក្រុងភ្នំពេញដើម្បីដាក់ពាក្យបណ្ដឹងជូនទៅស្ថាប័នរដ្ឋាភិបាល រដ្ឋសភា ឬអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗឡើយ។
- អាជ្ញាធរមូលដ្ឋានគ្មានសិទ្ធិតំរូវឱ្យអ្នកផ្ដល់ដំណឹងទៅពួកគេ មុននឹងអ្នកចូលរួមក្នុងកិច្ចប្រជុំ ឬធ្វើដំណើរនៅក្នុងតំបន់របស់អ្នក។

## សេរីភាពក្នុងការបញ្ចេញមតិ

- អ្នកមានសិទ្ធិប្ដឹងអំពី ប៉ូលិស អាជ្ញាធរមូលដ្ឋាន និងរដ្ឋាភិបាល
- អ្នកមានសិទ្ធិក្នុងការនិយាយស្ដី និងសរសេរអំពីអ្វីដែលអ្នកគិត
- ប៉ូលិស អាជ្ញាធរមូលដ្ឋាន និងរដ្ឋាភិបាល គ្មានសិទ្ធិហាមឃាត់អ្នកមិនឱ្យបញ្ចេញយោបល់ឡើយ

## សេរីភាពក្នុងការជួបប្រជុំ និងបង្កើតសមាគម

- អ្នកមានសិទ្ធិសេរីភាពជួបជុំគ្នាដោយសន្តិភាព ដើម្បីសម្ដែងមតិ និងផ្ដល់យោបល់ដែលពាក់ព័ន្ធ
- អ្នកមានសិទ្ធិសេរីភាពចូលរួម ឬបង្កើតក្រុម ឬសហជីព

## ប្រសិនបើសិទ្ធិរបស់លោក-អ្នកត្រូវគេរំលោភបំពាន:

- **សូមលោកអ្នកតាំងចិត្តឱ្យស្ងប់**
- **សូមកុំធ្វើការតបតដោយប្រើហិង្សា**
- **ផ្ដល់ព័ត៌មានទៅអាជ្ញាធរ តាមសិទ្ធិលោក-អ្នកមាន**
- **ទំនាក់ទំនងអង្គការក្រៅរដ្ឋាភិបាលដើម្បីសុំជំនួយ**
- **កត់ត្រានូវពេលវេលា ទីកន្លែង និងរឿងរ៉ាវនៃករណីដែលកើតឡើង**

# ទិវាសិទ្ធិមនុស្សអន្តរជាតិ

## ថ្ងៃទី ១០ ធ្នូ ២០០៨

## ខួបលើកទី ៦០ នៃសេចក្ដីប្រកាស ជាសកលស្ដីពីសិទ្ធិមនុស្ស



## យើងទាំងអស់គ្នាត្រូវការ សេរីភាព និងយុត្តិធម៌

**ក្រុមមិត្តភាព ថ្ងៃទី១០ ធ្នូ**

# សេរីភាពក្នុងការធ្វើដំណើរ

ជនណាក៏ដោយមានសិទ្ធិធ្វើដំណើរទៅមកនៅក្នុងប្រទេសរបស់អ្នកតាមបំណងប្រាថ្នា

### សិទ្ធិប្រឈមនឹងគ្រោះថ្នាក់

សេរីភាពក្នុងការធ្វើដំណើរ អាចមានផលវិបាកយ៉ាងខ្លាំងចំពោះសិទ្ធិមនុស្សជាមូលដ្ឋានដ៏ទៃទៀត។ គ្មានសេរីភាពក្នុងការធ្វើដំណើរ បុគ្គលនោះមិនអាចអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការបញ្ចេញមតិ ការជួបជុំ ឬការចូលរួម ។

### ករណីសិក្សានៅប្រទេសកម្ពុជា

**ករណីទី១:** នៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៨ អស់រយៈពេលជាងពីរសប្តាហ៍ ទាហានកងពលតូចលេខ ៣១ បានបិទច្រកផ្លូវទាំងអស់ទៅកាន់ភូមិជ័យសេនា ឃុំ-តាកែន ស្រុកឈូក ខេត្តកំពត ដោយបដិសេធន៍មិនឱ្យអ្នកស្រុក និងអង្គការក្រៅរដ្ឋាភិបាលធ្វើការចេញចូល។ ភូមិនោះមានជាប់ទាក់ទិននឹងជម្លោះដីធ្លីបន្ទាប់ពីអាជ្ញាធរខេត្ត បានអះអាងថាដីនោះត្រូវបានលក់ឱ្យទៅក្រុមហ៊ុនឯកជនមួយ។

**ករណីទី២:** នៅថ្ងៃទី២៣ ខែមិថុនា ២០០៨ ប៉ូលិសឃុំ និងអាជ្ញាធរមូលដ្ឋានបានព្យាយាមបង្ខាំងអ្នកភូមិនៅ ឃុំក្រាំងស្គៀរ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ដែលកំពុងធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញ ដើម្បីដាក់ពាក្យបណ្តឹងករណីរជម្លោះដីធ្លី។ អ្នកភូមិ ៤៣ នាក់ អាចធ្វើដំណើរមកដល់ទីក្រុងភ្នំពេញបាន បន្ទាប់ពីគេចខ្លួនចេញពីអាជ្ញាធរ។

**ករណីទី៣:** នៅថ្ងៃទី ៣០ ខែតុលា ២០០៨ អាជ្ញាធរបានប្រាប់អ្នកភូមិជនជាតិភាគតិចព្នងមកពីខេត្តមណ្ឌលគីរី ឱ្យទៅចុះឈ្មោះអំពីដំណើរចាកចេញពីខេត្តរបស់ពួកគេជាមួយមេឃុំ ដែលអ្នកភូមិកំពុងធ្វើដំណើរទៅកាន់ខេត្តរតនៈគីរី ដើម្បីចូលរួមធ្វើបាតុកម្មស្តីអំពីការរំលោភយកដីធ្លី។ អាជ្ញាធរមូលដ្ឋានបានអះអាងថាទង្វើរបស់ពួកគេ គឺដើម្បីសុវត្ថិភាពរបស់អ្នកភូមិ រីឯអង្គការក្រៅរដ្ឋាភិបាល និងអ្នកភូមិជាច្រើនបានចោទប្រកាន់អាជ្ញាធរពីបទបំភិតបំភ័យ។

### សិទ្ធិត្រូវបានធានានៅក្នុងរដ្ឋធម្មនុញ្ញ

មាត្រា ៤០: ត្រូវតែគោរពដល់សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋក្នុងការធ្វើដំណើរជិត ឬឆ្ងាយ និងការតាំងលំនៅស្ថានដោយស្របច្បាប់។ ប្រជាពលរដ្ឋខ្មែរត្រូវតែមានសិទ្ធិក្នុងការធ្វើដំណើរ និងតាំងលំនៅស្ថាននៅក្រៅប្រទេស និងវិលត្រឡប់មកប្រទេសវិញ។

# សេរីភាពក្នុងការនិយាយស្តី និងបញ្ចេញមតិ

មនុស្សគ្រប់រូបមានសិទ្ធិក្នុងការគិត និងបញ្ចេញយោបល់ ហើយគ្មាននរណាម្នាក់ហាមឃាត់អ្នកមិនឱ្យនិយាយស្តី ហើយអ្នកក៏អាចចែករំលែកគំនិតរបស់អ្នកបានដែរ។

### សិទ្ធិប្រឈមនឹងគ្រោះថ្នាក់

សេរីភាពក្នុងការបញ្ចេញមតិ គឺសំខាន់ក្នុងការជំរុញឱ្យលទ្ធិប្រជាធិបតេយ្យដំណើរការ និងការចូលរួមជាសាធារណៈ។ ប្រជាពលរដ្ឋគ្រប់រូបមិនអាចអនុវត្តសិទ្ធិ ដើម្បីបោះឆ្នោតប្រកបដោយប្រសិទ្ធិភាព ឬចូលរួមកិច្ចការនយោបាយបានទេ ប្រសិនបើពួកគេមិនទទួលបានព័ត៌មានដោយសេរី ហើយនិងមិនអាចបញ្ចេញគំនិតយោបល់ដោយសេរីបាន។

### ករណីសិក្សានៅប្រទេសកម្ពុជា

**ករណីទី១:** នៅខែមេសា ឆ្នាំ២០០៨ លោកឡឹម ពិសិដ្ឋ អ្នកសារព័ត៌មានវិទ្យុអាស៊ីសេរីត្រូវបានគេបង្ខំឱ្យគេចខ្លួនទៅកាន់ប្រទេសថៃបន្ទាប់ពីមានការគំរាមសំលាប់ទៅលើរូបគាត់។ តាំងពីដើមខែមេសា ឆ្នាំ២០០៨ លោកឡឹម ពិសិដ្ឋ បានស៊ើបអង្កេតលើករណីជួញដូរថ្នាំញៀន និងករណីធ្វើឃាតដែលតាមការចោទប្រកាន់ថា មានជាប់ពាក់ព័ន្ធនឹងមន្ត្រីដែលមានឋានៈខ្ពស់។

**ករណីទី២:** នៅថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០០៨ ស្ថានីយវិទ្យុក្នុងស្រុកមួយឈ្មោះអង្គររដ្ឋា អេហ្វអឹម ១០៥.២៥ ស្ថិតក្នុងខេត្តក្រចេះ ត្រូវបានបិទដោយរដ្ឋមន្ត្រីក្រសួងព័ត៌មាន ក្រោយពីបើកការផ្សាយបានតែ ១៣ ថ្ងៃប៉ុណ្ណោះ ដោយសារស្ថានីយនេះបានលក់ម៉ោងផ្សាយទៅឱ្យគណបក្សនយោបាយផ្សេងៗ ។ ហើយមកទល់ពេលនេះស្ថានីយវិទ្យុនេះនៅបន្តការបិទដដែល។

**ករណីទី៣:** ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៨ លោក ដាំ សិទ្ធិ និពន្ធនាយកកាសែតមនសិការខ្មែរ និងជាបេក្ខជនតំណាងរាស្ត្រនៃគណបក្សសម រង្ស៊ី ត្រូវចាប់ខ្លួនពីបទបរិហាកេរ្តិ៍។ គាត់ត្រូវបានធានាឱ្យនៅក្រៅឃុំបន្ទាប់ពីមួយសប្តាហ៍ក្រោយមក។

**ករណីទី៤:** នៅថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៨ លោក ឃឹម សម្បូរណ៍ អ្នកសារព័ត៌មានកាសែតមនសិកាខ្មែរ ដែលជាការសែតគាំទ្រគណបក្សប្រឆាំង និងកូនប្រុសរបស់លោកឈ្មោះ ខាត់ សារិន្ទភាតា ត្រូវបានបាញ់ស្លាប់នៅវេលាម៉ោង ៧ ល្ងាចជិតស្តាតអូឡាំពិក ដោយជនមិនស្គាល់មុខ ២ នាក់ ដែលជិះម៉ូតូ។ ហើយអ្នកសំលាប់នោះមិនត្រូវបានគេរកឃើញទេ។

### សិទ្ធិត្រូវបានធានានៅក្នុងរដ្ឋធម្មនុញ្ញ

មាត្រា ៤១: ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិសេរីភាពខាងសារព័ត៌មាននិងការជួបជុំគ្នា។ គ្មាននរណាម្នាក់ត្រូវអនុវត្តនូវការរំលោភលើសិទ្ធិរបស់អ្នកដទៃ ធ្វើឱ្យប៉ះពាល់ដល់សង្គម រំលោភច្បាប់សាធារណៈ សណ្តាប់ធ្នាប់ និងសន្តិសុខជាតិជាដាច់ខាត។

# សេរីភាពក្នុងការជួបប្រជុំ និងបង្កើតសមាគម

មនុស្សគ្រប់រូបមានសិទ្ធិដើម្បីរៀបចំការជួបជុំដោយសន្តិភាព ឬចូលរួមក្នុងការប្រជុំដោយសន្តិភាព។ វាជាការខុសដែលអាជ្ញាធរបញ្ឈប់នរណាម្នាក់មិនឱ្យចូលរួម ឬបង្កើតក្រុម។

### សិទ្ធិប្រឈមនឹងគ្រោះថ្នាក់

សិទ្ធិក្នុងការបង្កើតក្រុម ចូលរួមសហជីព និងរៀបចំប្រមូលផ្តុំគ្នាជាមួយនឹងគោលបំណងដែលបង្ហាញអំពីបញ្ហាជារួម គឺជាសិទ្ធិមនុស្ស។ វាជាមធ្យោបាយ មួយដ៏សំខាន់ អាចឱ្យប្រជាពលរដ្ឋគ្រប់រូប ជះឥទ្ធិពលដល់រដ្ឋាភិបាល និងថ្នាក់ដឹកនាំរបស់ពួកគេ។

### ករណីសិក្សានៅប្រទេសកម្ពុជា

**ករណីទី១:** នៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០០៨ កម្មករ ៣០០នាក់ នៅសហជីពយុវជនខ្មែរ ដែលធ្វើការនៅក្រុមហ៊ុនឧស្សាហកម្មសំលៀកបំពាក់កម្ពុជានៅខេត្តកំពង់ស្ពឺ ធ្វើកូដកម្មអហិង្សាមួយដើម្បីដើម្បីតវ៉ាអំពីការរំលោភលើសិទ្ធិពលកម្ម និងបណ្តេញចេញកម្មករបណ្តែតចំនួន ៧៨ នាក់ និងអ្នកដឹកនាំសហជីពចំនួន ៣ នាក់ទៀត។ នៅពេលដែល កម្មករបានប៉ុនប៉ងទប់ស្កាត់រោងចក្ររារាំងមិនឱ្យនាំចេញនូវផលិតផល ប៉ូលិសបានមកដល់រោងចក្រដោយកាន់ដំបង និងរបាំងការពារដើម្បីបង្ក្រាបក្រុមបាតុករ។

**ករណីទី២:** នៅថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០០៨ កម្មកររោងចក្រ ១១ នាក់បានទទួលរងរបួស និង៥ នាក់ ផ្សេងទៀតបានសំរាកព្យាបាលក្នុងមន្ទីរពេទ្យបន្ទាប់ពីប៉ូលិសប៉ុនប៉ងបង្ក្រាបទៅលើកូដកម្មនៅខាងក្រៅរោងចក្រសំលៀកបំពាក់ ឃើងឡែន។ កម្មករបានធ្វើកូដកម្ម តាំងពីថ្ងៃទី១១ ខែមករា ទាមទារឱ្យមានការគោរពច្បាប់ការងារ និងប្រគល់ការងារឡើងវិញឱ្យអ្នកតំណាងសហជីព ១៩ នាក់ ដែលបានបណ្តេញចេញកាលពីខែមិថុនា ឆ្នាំ២០០៧។

**ករណីទី៣:** នៅថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០០៨ កម្មកររោងចក្របានប៉ុនប៉ងជួបជុំគ្នាដោយសន្តិភាពអំពីជម្លោះប្រាសាទព្រះវិហារ។ ប៉ូលិសផ្នែកអន្តរាគមន៍ ៥០ នាក់បានតតាំងគ្នាជាមួយកម្មករ និងគ្រូបង្រៀន ១០០ នាក់ និងបានបញ្ឈប់ពួកគេមិនឱ្យធ្វើការដង្ហែក្បួននៅតាមដងវិថី។ ប៉ូលិសបានរុញច្រានបាតុករព្រមទាំងបានបំផ្លាញបដា និងរឹបអូសយកទង់ជាតិកម្ពុជាទៀតផង។

### សិទ្ធិត្រូវបានធានានៅក្នុងរដ្ឋធម្មនុញ្ញ

មាត្រា ៤២ ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវមានសិទ្ធិបង្កើតសមាគមន៍ និងគណបក្សនយោបាយ។ សិទ្ធិទាំងនេះសំរេចដោយច្បាប់។ ប្រជាពលរដ្ឋខ្មែរគ្រប់រូបអាចចូលរួមចំនែកក្នុងការប្រមូលផ្តុំជាលក្ខណៈទ្រង់ទ្រាយធំសំរាប់ប្រយោជន៍ទៅវិញទៅមកដើម្បីការពារសមិទ្ធិផលជាតិ និងសណ្តាប់ធ្នាប់សង្គម។